**THE COMMONWEALTH OF MASSACHUSETTS**
**THE TRIAL COURT**
**PROBATE AND FAMILY COURT ADMINISTRATIVE OFFICE**
**Three Center Plaza, Suite 210**
**Boston, MA  02108**

**John D. Casey**
**Chief Justice**

**TEL: (617) 788-6600**
**FAX: (617) 788-8995**

ខែមីនា 24, 2020

សួរស្តី,

នេះគឺជាពេលវេលាដ៏លំបាកសម្រាប់មនុស្សគ្រប់គ្នា  រួមទាំងបុគ្គលិកទាំងអស់នៃតុលាការមរតកនិងគ្រួសារ  និងបុគ្គលិកនៃស្ថាប័នតុលាការវិនិច្ឆ័យក្តីផ្សេងទៀត។ ខ្ញុំសូមថ្លែងអំណរគុណជាសាធារណៈដល់បុគ្គលិក សមាគមន៍មេធាវី និងដៃគូរបស់យើងទាំងអស់ដែលធ្វើការជាមួយគ្នាដើម្បីធានាថា យើងអាចផ្តល់យុត្តិធម៌ដល់បុគ្គលទាំងឡាយណាដែលត្រូវការយើង។

វាជាកាលទេសៈដូចនេះ នៅពេលដែលសង្គមប្រឈមមុខនឹងការគំរាមកំហែងដែលពីមុននឹកស្មានមិនដល់ ថាច្បាប់គឺសំខាន់ជាងពេលណាៗ ទាំងអស់។ ដោយសារតែការយកចិត្តទុកដាក់ និងលះបង់ខ្ពស់របស់បុគ្គលិក យើងនៅតែមានលទ្ធភាពដើម្បីចេញបញ្ជា  និងអនុវត្តបញ្ជាដែលមានស្រាប់នៅក្នុងស្ថានភាពអាសន្ន។ ប្រសិនបើលោក-អ្នកប្រឈមកាលៈទេសៈពិសេស/ចាំបាច់ លោក-អ្នកគួរតទាក់ទងតុលាការក្នុងតំបន់របស់អ្នក។

បញ្ហាសម្រាប់ឪពុកម្តាយជួបកូនមិនត្រូវបានរក្សាទុកនៅក្នុងរយៈពេលនេះទេ។ តាមពិត វាជាការសំខាន់ណាស់ដែលកូនៗ ចំណាយពេលជាមួយទាំងឪពុកម្តាយរបស់ពួកគេ ហើយឪពុកម្តាយម្នាក់ៗ មានឱកាសចូលរួមសកម្មភាពគ្រួសារដែលត្រូវផ្តល់ជូនតាមបញ្ជារបស់តុលាការ។ ក្នុងករណីដែលឪពុកឬម្តាយត្រូវរក្សាខ្លួនឱ្យដាច់ពីគេ ឬបើពុំដូច្នោះទេ ត្រូវបានគេដាក់កម្រិតមិនឱ្យទាក់ទងជាមួយអ្នកដទៃ ឪពុកម្តាយទាំងពីរគួរតែសហការគ្នាដើម្បីអនុញ្ញាតឱ្យមានពេលវេលាសម្រាប់ជួបឪពុកម្តាយនោះតាមរយៈវីឌីអូ ឬទូរស័ព្ទ។ ដើម្បីជួយដល់មាតាបិតា ហើយជាលទ្ធផលដើម្បីឱ្យមាតាបិតានោះអាចជួយកូនៗ របស់ពួកគាត់ យើងបានកែសម្រួលតម្រូវការការអប់រំឪពុកម្តាយដែលជាការចាំបាច់។ ព័ត៌មានអំពីបញ្ហានេះអាចរកបាននៅ: https://www.mass.gov/advisory/clarification-to-parent-education-procedures-in-section-h-1-of-probate-and-family-court.

មានព័ត៌មាននៅលើគេហទំព័ររបស់យើងអំពីការធ្វើជាឪពុកម្តាយរួមគ្នាក្នុងកំឡុងពេលតានតឹង និងលំបាកនេះ។ តំណភ្ជាប់គឺ: https://www.afccnet.org/Coronavirus. លើសពីនេះ ថ្នាក់ដឹកនាំនៃសមាគមគ្រួសារ និងតុលាការផ្សះផ្សា និងវិជ្ជាស្ថានសិក្សាអាមេរិកនៃមេធាវីទាក់ទងពិធីរៀបការបានផ្សព្វផ្សាយគោលការណ៍ណែនាំទាំងប្រាំពីរនេះសម្រាប់មាតាបិតាដែលបានលែងលះគ្នា/ចែកផ្លូវគ្នា និងមានការចែករំលែកការថែរក្សាកូនៗ ក្នុងកំឡុងពេលជំងឺរាតត្បាតកូវីដ-19 នេះ។ គោលការណ៍នោះអាចរកបាននៅ: https://www.afccnet.org/Portals/0/COVID19Guidelinesfordivorcedparents.FINAL.pdf?ver=2020-03-17-202849-133 និងនៅលើគេហទំព័ររបស់យើង។

/s/ John D. Casey
ចៅក្រម John D. Casey
ប្រមុខចៅក្រម ( Chief Justice)
តុលាការផ្នែកមរតក និងគ្រួសារ